មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌
# សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ

www.cchrcambodia.org

លេខ៧ - ខែមេសា ឆ្នាំ២០១៩

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) បានធ្វើការសង្កេតការណ៍សវនាការចាប់ពីឆ្នាំ២០០៩ ដើម្បីតាមដានសវនាការព្រហ្មទណ្ឌនៅតុលាការកម្ពុជា និងវាយតម្លៃអំពីការអនុវត្តការជំនុំជម្រះដោយយុត្តិធម៌តាមបទដ្ឋានជាតិ និងអន្តរជាតិ។ ចាប់តាំងពីខែមីនា ឆ្នាំ២០១៣ គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៃ ម.ស.ម.ក បានសង្កេតសវនាការនៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។ ព្រឹត្តិបត្រព័ត៌មាននេះ គឺជាផ្នែកនៃការចេញផ្សាយជាស៊េរីប្រចាំត្រីមាស ដែលវិភាគលើរបកគំហើញពីការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក និងពិភាក្សាបញ្ហាឲ្យបានទូលំទូលាយ។ ព្រឹត្តិបត្រព័ត៌មាននេះ ផ្តោតលើបញ្ហាប្រឈមចំពោះប្រជាពលរដ្ឋកម្ពុជា ដែលរងការចោទប្រកាន់ក្នុងរឿងព្រហ្មទណ្ឌ ជាពិសេសការទទួលបានមេធាវី និងសិទ្ធិមានវត្តមាននៅពេលសវនាការលើរឿងក្តីរបស់ពួកគេ។

**ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា**
**មាត្រា ៣០០**

"ជនជាប់ចោទត្រូវចូលបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់។ ជនជាប់ចោទត្រូវអមដោយមេធាវីម្នាក់ដែលខ្លួនជ្រើសរើស។ ជនជាប់ចោទក៏អាចសុំឲ្យចាត់តាំងមេធាវីឲ្យខ្លួនបានដែរ នៅក្នុងលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីលក្ខន្តិកៈមេធាវី។"

**កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ មាត្រា ១៤(៣)(ឃ)**

"ក្នុងការសម្រេចសេចក្តី ចោទប្រកាន់ពីបទព្រហ្មទណ្ឌណាមួយប្រឆាំងមកលើខ្លួន ជនគ្រប់រូបមានសិទ្ធិទទួលបាន៖ ការជំនុំជម្រះដោយមានវត្តមានរបស់ខ្លួន និងការពារខ្លួនដោយផ្ទាល់ខ្លួនឯង ឬតាមរយៈជំនួយការច្បាប់តាមការជ្រើសរើសរបស់ខ្លួន និងត្រូវបានប្រាប់ឲ្យដឹងអំពីសិទ្ធិនេះ ប្រសិនបើខ្លួនគ្មានជំនួយការច្បាប់ ហើយត្រូវទទួលបានជំនួយការច្បាប់សម្រាប់ខ្លួន ក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ និងដោយឥតបង់ថ្លៃនៅគ្រប់ករណីបែបនេះ បើជនជាប់ចោទគ្មានមធ្យោបាយគ្រប់គ្រាន់ដើម្បីចំណាយទៅលើជំនួយការច្បាប់ទេ។"

## *សិទ្ធិមានមេធាវី*

ផ្នែកមួយដ៏សំខាន់នៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ គឺការមានឱកាសទទួលបានមេធាវី។ នីតិវិធីច្បាប់អាចមានភាពស្មុគស្មាញ និងអាចមានការភាន់ច្រឡំ ហើយប្រសិនបើគ្មានមេធាវីតំណាង បុគ្គលដែលរងការចោទប្រកាន់រឿងព្រហ្មទណ្ឌទំនងជាខាតប្រយោជន៍ អាចដោយសារតែខ្វះចំណេះដឹងផ្នែកច្បាប់ និងប្រព័ន្ធតុលាការ និងដោយសារតែគ្មានមេធាវីតំណាងនៅតុលាការ។ លើសពីនេះទៀត សិទ្ធិមានមេធាវីរបស់បុគ្គលរងការចោទប្រកាន់រឿងព្រហ្មទណ្ឌមិនគួរត្រូវបានកម្រិតដោយការមិនមានលទ្ធភាពជួលមេធាវីនោះទេ។ នៅពេលដែលបុគ្គលនោះមិនមានលទ្ធភាពជួលមេធាវី ច្បាប់តម្រូវថាអាជ្ញាធរពាក់ព័ន្ធគួរផ្តល់មេធាវីដោយគ្មានការបង់សេវា។

## *សិទ្ធិមានវត្តមាននៅពេលសវនាការ*

សិទ្ធិមានវត្តមាននៅពេលសវនាការ គឺជាមូលដ្ឋានគ្រឹះមួយនៃសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ សិទ្ធិនេះមានភាពចាំបាច់ដែលភាគីជនជាប់ចោទ ត្រូវបានអនុញ្ញាតឲ្យនៅក្នុងតុលាការអំឡុងពេលសវនាការ។ វត្តមាននៅពេលសវនាការផ្ទាល់របស់ជនជាប់ចោទមានសារៈសំខាន់ណាស់ដោយសិទ្ធិនេះអនុញ្ញាតឲ្យជនជាប់ចោទដឹងអំពីសំណុំរឿងរបស់ខ្លួន និងតតាំងលើករណីដែលប្រឆាំងនឹងខ្លួនគេ និងបង្ហាញពីការការពារខ្លួន។ ការជំនុំជម្រះដោយគ្មានវត្តមានជនជាប់ចោទ គឺរារាំងលទ្ធភាពរបស់ជនជាប់ចោទ ដើម្បីការពារខ្លួនរបស់ពួកគេ និងធ្វើឲ្យសវនាការនោះជាសវនាការមិនស្របច្បាប់។

## *ក្របខ័ណ្ឌច្បាប់*

ច្បាប់កម្ពុជាចែងអំពីសិទ្ធិទាំងនេះក្នុងក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា មាត្រា ៣០០ ដែលតម្រូវឲ្យជនជាប់ចោទ ចូលបង្ហាញខ្លួនដោយផ្ទាល់ នៅពេលសវនាការរបស់តុលាការ និងចែងថាជនជាប់ចោទ"អាច" ស្នើសុំមេធាវីបាន។

មាត្រា ៣០១ នៃក្រមនេះបានចែងថា ជំនួយពីមេធាវីត្រូវតែមានដាច់ខាតក្នុងលក្ខខណ្ឌពីរ៖ ករណីបទឧក្រិដ្ឋ និងជនជាប់ចោទជាអនីតិជន។ ថ្វីបើច្បាប់ជាតិបានធានាយ៉ាងច្បាស់នូវសិទ្ធិមានមេធាវីសម្រាប់ជនជាប់ចោទជាអនីតិជន និងជនជាប់ចោទដែលរងការចោទប្រកាន់ពីបទឧក្រិដ្ឋ ប៉ុន្តែច្បាប់នេះ មិនទាន់ស្របតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិនៅឡើយ ចំពោះករណីដែលពាក់ព័ន្ធនឹងបទល្មើសផ្សេងទៀតក្រៅពីបទឧក្រិដ្ឋ ឧទាហរណ៍ដូចជា បទមជ្ឈិមជាដើម។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិ មិនបានបែងចែកបទល្មើសផ្សេងគ្នាដូច្នេះទេ ហើយផ្ទុយមកវិញ គឺតម្រូវឲ្យមានសិទ្ធិមានមេធាវី ដែលត្រូវតែអនុវត្តជាសាកល និងមិនគិតពីបទល្មើសឡើយ។

សិទ្ធិមានវត្តមាននៅពេលសវនាការក៏បានចែងនៅក្នុងច្បាប់ជាតិ និងអន្តរជាតិផងដែរ។ ក្រមនីតិវិធីព្រហ្មទណ្ឌបានចែងថាជនជាប់ចោទមានសិទ្ធិ"បង្ហាញខ្លួនដោយផ្ទាល់"នៅពេលសវនាការ ហើយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ តម្រូវថាការជំនុំជម្រះត្រូវធ្វើឡើងដោយ"មានវត្តមាន"របស់ជនជាប់ចោទ។ ការជំនុំជម្រះដោយកំបាំងមុខមិនត្រូវបានអនុញ្ញាតតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ទោះយ៉ាងនេះក្តី ការជំនុំជម្រះនេះអាចត្រូវបានអនុញ្ញាតនៅក្នុងតែករណីពិសេស និងនៅក្នុងករណីដែលផលប្រយោជន៍យុត្តិធម៌តម្រូវឲ្យធ្វើដូច្នេះ។

cc BY NC SA

## *សិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការ ជាតួលេខ*
## *របកគំហើញនៃការសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក*

ការសង្កេតការណ៍សវនាការប្រចាំថ្ងៃរបស់គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅសាលាឧទ្ធរណ៍នៅចន្លោះថ្ងៃទី០១ ខែវិច្ឆិកា ឆ្នាំ២០១៧ ដល់ថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៩ បានប្រមូលទិន្នន័យនៃសំណុំរឿងចំនួន ៣០១ ដែលមានជនជាប់ចោទចំនួន ៤៥៣នាក់។ គម្រោងបានវិភាគលើការអនុវត្តតាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅក្នុងសវនាការនៃសំណុំរឿងព្រហ្មទណ្ឌនីមួយៗ និងកម្រិតនៃការការពារសិទ្ធិមានមេធាវី និងមានវត្តមាននៅពេលសវនាការរបស់ជនជាប់ចោទនីមួយៗ។

ចំនួន២៥% (១១១) នៃជនជាប់ចោទទាំងអស់ ដែល ម.ស.ម.ក បានសង្កេតការណ៍ មិនមានវត្តមានមេធាវីការពារ។ បញ្ហានេះបង្ហាញថា ជនជាប់ចោទម្នាក់ក្នុងចំណោមបួននាក់នៅសាលាឧទ្ធរណ៍ មិនបានទទួលនូវសិទ្ធិមានមេធាវីរបស់ពួកគេឡើយ។ ដោយអនុលោមតាមច្បាប់ជាតិដែលផ្តល់ការការពារបន្ថែមចំពោះជនជាប់ចោទជាអនីតិជន និងជនជាប់ចោទពីបទឧក្រិដ្ឋ មិនមានសំណុំរឿងណាមួយដែលត្រូវបានរកឃើញថាជនជាប់ចោទជាអនីតិជន និងជនជាប់ចោទពីបទឧក្រិដ្ឋ មិនមានមេធាវីការពារនោះឡើយ។ ហេតុដូច្នេះ សំណុំរឿងទាំងអស់ដែលពាក់ព័ន្ធនឹងបទឧក្រិដ្ឋ និង/ឬអនីតិជន គឺមានមេធាវីតំណាង។




ទិន្នន័យដែល ម.ស.ម.ក បានសង្កេតការណ៍ក៏បង្ហាញថា ក្នុងសំណុំរឿងចំនួន ០៧ មានទំនាស់ផលប្រយោជន៍នឹងគ្នា នៅពេលដែលមេធាវីម្នាក់តំណាងឲ្យជនជាប់ចោទច្រើននាក់។




គម្រោងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ក៏បានរកឃើញថា នៅក្នុងអំឡុងពេលសង្កេតការណ៍ ជនជាប់ចោទចំនួន ៨៤នាក់ មិនមានវត្តមាននៅពេលសវនាការរបស់ពួកគេ។ ចំនួននេះស្មើនឹង ១៩% នៃជនជាប់ចោទដែលត្រូវបានសវនាការដោយកំបាំងមុខ ហេតុដូចនេះ សវនាការទាំងនេះគឺមិនអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ ចំពោះសិទ្ធិមានវត្តមាននៅពេលសវនាការឡើយ។ ការស្រាវជ្រាវរបស់ ម.ស.ម.ក ក៏បានរកឃើញផងដែរថា សំណុំរឿងភាគច្រើន ការអវត្តមានរបស់ជនជាប់ចោទនៅពេលសវនាការ គឺដោយសារតែកង្វះមធ្យោបាយដឹកជញ្ជូនជនជាប់ចោទពីមណ្ឌលឃុំខ្លួនមកតុលាការ។

### **អនុសាសន៍**

ម.ស.ម.ក សូមអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជា និងចៅក្រម ធានានូវការអនុវត្តដូចខាងក្រោម៖

- សាលាឧទ្ធរណ៍ និងអគ្គនាយកដ្ឋានពន្ធនាគារគួរពិគ្រោះយោបល់ និងសម្របសម្រួលគ្នា ដើម្បីដោះស្រាយបញ្ហាភ័ស្តុភារ និងការប្រាស្រ័យទាក់ទងឲ្យបានឆាប់រហ័សតាមដែលអាចធ្វើបាន ចំពោះទីតាំងនៃជនជាប់ចោទ និងជាពិសេស៖
  - អគ្គនាយកដ្ឋានពន្ធនាគារត្រូវធានាថា ព័ត៌មានស្តីពីការផ្ទេរជនជាប់ឃុំត្រូវបានបញ្ជូនជាទៀងទាត់ទៅកាន់ព្រះរាជអាជ្ញា។
  - សាលាឧទ្ធរណ៍ត្រូវធានាថា ព័ត៌មានទាក់ទងនឹងកាលបរិច្ឆេទ និងពេលវេលានៃសវនាការរបស់ខ្លួនត្រូវបានបញ្ជូនឲ្យបានត្រឹមត្រូវទៅមណ្ឌលកែប្រែនៃជនជាប់ចោទនោះដែលកំពុងជាប់ឃុំ។
- ចៅក្រមនៃសាលាឧទ្ធរណ៍គួរពន្យារពេលសវនាការ ប្រសិនជនជាប់ចោទមិនមានវត្តមាន បើទោះបីជាជនជាប់ចោទនោះមានមេធាវីតំណាងក៏ដោយ លុះត្រាតែជនជាប់ចោទនោះបានលះបង់សិទ្ធិមានវត្តមាននៅពេលសវនាការដោយជាក់លាក់ និងជាផ្លូវការ។
- ចៅក្រមគួរគោរពសិទ្ធិមានមេធាវីជាលក្ខណៈសាកលដូចមានចែងក្នុងច្បាប់អន្តរជាតិ ដោយមិនត្រូវកំណត់ទៅតាមប្រភេទនៃបទល្មើសនោះទេ។

cc BY NC SA

ព្រឹត្តិបត្រព័ត៌មានស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ ម.ស.ម.ក លេខមុនៗ អាចរកបានតាមប្រព័ន្ធអ៊ីនធឺណិត (លេខ១ លេខ២ លេខ៣ លេខ៤ លេខ៥ និងលេខ៦)។ លោកអ្នកក៏អាចអានរបាយការណ៍ប្រចាំឆ្នាំ២០១៧ របស់យើង ស្តីពី "សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា ការសង្កេតការណ៍សវនាការនៅសាលាឧទ្ធរណ៍" ដែលបានបង្ហាញពីរបកគំហើញសំខាន់ៗពីការសង្កេតការណ៍របស់ខ្លួននៅសាលាឧទ្ធរណ៍ក្នុងរាជធានីភ្នំពេញពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០១៦ ដល់ថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧។

BY NC SA